ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្ដីប្រកាសព័ត៌មាន របស់ក្រសួងសុខាភិបាល

ដោយពិនិត្យឃើញថា ស្ថានភាពជំងឺគ្រុនផ្ដាសាយថ្មី A(H1N1) កំពុងតែមានការរីករាលដាលកាន់តែរហ័សឡើងៗ ជារៀងរាល់ថ្ងៃ ជាពិសេស ឆ្លងតាមអ្នកដំណើរចេញ-ចូលទៅប្រទេសថៃ។

ដើម្បីទប់ស្កាត់កុំឱ្យការរីករាលដាលនៃការឆ្លងមេរោគគ្រុនផ្ដាសាយថ្មី A(H1N1) មានទ្រង់ទ្រាយធំថែមទៀត ក្រសួង សុខាភិបាល សូមធ្វើការប្រកាស ជូនសាធារណៈជន ដូចខាងក្រោម:

១-សូមសាធារណជនផ្អាកធ្វើដំណើរចេញ-ចូលទៅប្រទេសថៃ មួយរយៈ បើគ្មានការចាំបាច់

២-បើជនណាម្នាក់យល់ឃើញថា ជាការចាំបាច់ពុំអាចជៀសវាងបាន សូមអនុវត្តឱ្យបានដាច់ខាតនូវការណែនាំរបស់ក្រសួងសុខាភិបាល ដូចខាងក្រោម:

-ក្នុងពេលស្នាក់នៅបរទេស ត្រូវជៀសវាងទៅកាន់ទីកន្លែងប្រមូលផ្ដុំ ដែលមានមនុស្សច្រើន

-មិនត្រូវទៅជិតអ្នកដែលមានជំងឺផ្ដាសាយថ្មី A(H1N1) ឬមានរោគសញ្ញា ដូចជំងឺផ្ដាសាយ

-ត្រូវលាងដៃជាមួយសាប៊ូ ឬទឹកអាល់កុល ឱ្យបានញឹកញាប់

-មិនត្រូវយកដៃញីភ្នែក ឬច្រមុះ

-ពេលត្រឡប់ចូលប្រទេសវិញ ត្រូវបំពេញទម្រង់ប្រកាសសុខភាពឱ្យបានត្រឹមត្រូវ ដើម្បីឱ្យមន្ត្រីសុខាភិបាលងាយតាមដានស្ថានភាពសុខភាព ហើយសូមរក្សាប័ណ្ណព័ត៌មានសុខភាពឱ្យបានគង់វង្ស

-បើសិនមានរោគសញ្ញា ដូចជា គ្រុនក្ដៅលើស ៣៨អង្សា និងក្អក ឬ ឈឺ ក សូមរាយការណ៍មកទូរស័ព្ទលេខ ១១៥ ឬ ០១២ ៤៨៨ ៩៨១ ឬ ០៨៩ ៦៦៩ ៥៦៧ ឬទាក់ទងមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលនៅជិតគេហដ្ឋានរបស់អស់លោក លោកស្រី។

ក្រសួងសុខាភិបាលសង្ឃឹមថា សាធារណៈជននឹងរួមសហការជាមួយក្រសួងសុខាភិបាលក្នុងការអនុវត្តវិធានការនេះ។

ភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីប្រកាសព័ត៌មាន របស់ក្រសួងសុខាភិបាល

ដោយពិនិត្យឃើញថា ស្ថានភាពជំងឺគ្រុនផ្តាសាយថ្មី A(H1N1) កំពុងតែមានការរីករាលដាលកាន់តែរហ័សឡើងៗ ជារៀងរាល់ថ្ងៃ ជាពិសេស ឆ្លងតាមអ្នកដំណើរចេញ-ចូលទៅប្រទេសថៃ។

ដើម្បីទប់ស្កាត់កុំឱ្យការរីករាលដាលនៃការឆ្លងមេរោគគ្រុនផ្តាសាយថ្មី A(H1N1) មានទ្រង់ទ្រាយធំថែមទៀត ក្រសួង សុខាភិបាល សូមធ្វើការប្រកាស ជូនសាធារណៈជន ដូចខាងក្រោម:

១-សូមសាធារណជនផ្អាកធ្វើដំណើរចេញ-ចូលទៅប្រទេសថៃ មួយរយៈ បើគ្មានការចាំបាច់

២-បើជនណាម្នាក់យល់ឃើញថា ជាការចាំបាច់ពុំអាចជៀសវាងបាន សូមអនុវត្តឱ្យបានដាច់ខាតនូវការណែនាំរបស់ក្រសួងសុខាភិបាល ដូចខាងក្រោម:

-ក្នុងពេលស្នាក់នៅបរទេស ត្រូវជៀសវាងទៅកាន់ទីកន្លែងប្រមូលផ្តុំ ដែលមានមនុស្សច្រើន

-មិនត្រូវទៅជិតអ្នកដែលមានជំងឺផ្តាសាយថ្មី A(H1N1) ឬមានរោគសញ្ញា ដូចជំងឺផ្តាសាយ

-ត្រូវលាងដៃជាមួយសាប៊ូ ឬទឹកអាល់កុល ឱ្យបានញឹកញាប់

-មិនត្រូវយកដៃញីភ្នែក ឬច្រមុះ

-ពេលត្រឡប់ចូលប្រទេសវិញ ត្រូវបំពេញទម្រង់ប្រកាសសុខភាពឱ្យបានត្រឹមត្រូវ ដើម្បីឱ្យមន្ត្រីសុខាភិបាលងាយតាមដានស្ថានភាពសុខភាព ហើយសូមរក្សាប័ណ្ណព័ត៌មានសុខភាពឱ្យបានគង់វង្ស

-បើសិនមានរោគសញ្ញា ដូចជា គ្រុនក្តៅលើស ៣៨អង្សា និងក្អក ឬ ឈឺ ក សូមរាយការណ៍មកទូរស័ព្ទលេខ ១១៥ ឬ ០១២ ៤៨៨ ៩៨១ ឬ ០៨៩ ៦៦៩ ៥៦៧ ឬទាក់ទងមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលនៅជិតគេហដ្ឋានរបស់អស់លោក លោកស្រី។

ក្រសួងសុខាភិបាលសង្ឃឹមថា សាធារណៈជននឹងរួមសហការជាមួយក្រសួងសុខាភិបាលក្នុងការអនុវត្តវិធានការនេះ។

ភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០៩